# ព្រះគម្ពីរសម្រាប់កុមារ
សូមបង្ហាញជូន

# ដើមកំណើតនៃសេចក្តីទុក្ខ
# ព្រួយរបស់មនុស្ស



និពន្ធដោយ: Edward Hughes

ធ្វើការពន្យល់ដោយ: Byron Unger; Lazarus

កែសម្រួលដោយ: M. Maillot; Tammy S.

បកប្រែដោយ: Christian Lingua

ផលិតដោយ: Bible for Children
www.M1914.org

©2018 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ អ្នកមានសិទ្ធិក្នុងការចម្លង ឬបោះពុម្ពរឿងនេះបាន ដរាបណាអ្នកមិនយកទៅលក់។


ព្រះបានបង្កើតរបស់
គ្រប់ទាំងអស់! នៅពេលព្រះអ
ង្គបានបង្កើតមនុស្សដំបូងមក
គឺលោកអ័ដាម
នោះគាត់ក៏រស់នៅក្នុង
សួនអេដានជាមួយ
...


... ប្រពន្ធរបស់គាត់
គឺនាងអេវ៉ា។ ពួកគាត់សប្បា
យចិត្តក្នុងការស្តាប់បង្គាប់ព្រះ
ហើយក៏មានអំណរក្នុងព្រះវត្ត
មានរបស់ទ្រង់ផង
រហូតដល់ថ្ងៃមួយ
...



ពស់បានសួរនាងអេវ៉ាថា
“តើព្រះបានប្រាប់អ្នកមិនឲ្យ
បរិភោគផ្លែពីដើមឈើ
ណាមួយមែនទេ?”



នាងបានឆ្លើយថា
“យើងអាចបរិភោ
គផ្លែឈើគ្រប់ទាំងអ
ស់ លើកលែងតែមួយប៉ុណ្ណោះ។
បើយើងបរិភោគ ឬក៏ប៉ះពាល់វា
នោះយើងនឹងត្រូវស្លាប់។”
ពស់ចំអកឲ្យនាងថា
“អ្នកនឹងមិនស្លាប់ទេ។”



“អ្នកនឹងបានដូចជាព្រះ។”
នាងអេវ៉ាចង់បានផ្លែពីដើមឈើនោះ។
នាងបានស្តាប់តាមពស់
ហើយក៏បានបរិភោ
គផ្លែឈើនោះទៅ។

ក្រោយពេលដែលអេវ៉ា
មិនស្ដាប់បង្គាប់ព្រះហើយ
នោះនាងក៏បាននាំអ័ដាមឲ្យ
បរិភោគផ្លែឈើនោះដែរ។
អ័ដាមគួរតែបាន
ប្រកែកថា “ទេ!
ខ្ញុំនឹងមិនអាច
មិនស្ដាប់បង្គាប់
ព្រះបន្ទូល
របស់ព្រះ
នោះទេ។”





នៅពេលអ័ដាម និងអេវ៉ាបានធ្វើបាប នោះពួកគាត់ក៏បានដឹងថាខ្លួនឯងនៅអាក្រាត។ ពួកគាត់ក៏បានយកស្លឹកល្វាមកដេរក្លាស់ធ្វើជាប្រដាប់បិទបាំងខ្លួនប្រាណ ...



... ហើយក៏បានពួននៅក្នុងគុម្ពោតព្រៃ
ដើម្បីលាក់ខ្លួនពីព្រះវត្តមាននៃព្រះ។

នៅក្នុងវេលាល្ងាចដ៏ត្រជាក់ស្រួលមួយ ព្រះទ្រង់
បានយាងមកសួនច្បារ។ ទ្រង់បានជ្រាបអំ
ពីអ្វីដែលអ័ដាម និងអេវ៉ាបានធ្វើ។
អ័ដាមបានបន្ទោសអេវ៉ា។
អេវ៉ាបានបន្ទោសពស់។
ព្រះទ្រង់មានបន្ទូលថា ...




… “ពស់ត្រូវបណ្ដាសាហើយ។ រីឯស្ត្រីនឹងមា
នការឈឺចាប់ពេលបង្កើតកូន។”
“អ័ដាម ដោយព្រោះតែឯងបានធ្វើបាប
នោះដីក៏ត្រូវបណ្ដាសាឲ្យដុះជាបន្លា
និងអញ្ចាញ។ ឯងនឹងត្រូវធ្វើការនឿ
យហត់ ហើយចេញញើសដើម្បីឲ្យ
បានអាហារបរិភោ
គប្រចាំថ្ងៃ។”



ព្រះបានបណ្ដេញអ័ដាម
និងអេវ៉ាចេញពីសួនច្បារដ៏
អស្ចារ្យ។ ព្រោះពួកគេបាន
ធ្វើបាប ទើបពួកគេត្រូវ
ដាច់ចេញឆ្ងាយពីព្រះ
ដ៏ប្រទានឲ្យមានជីវិត!


ព្រះបានដាក់ដាវជាអណ្ដាត
ភ្លើងដើម្បីការពារកុំឲ្យពួកគាត់ចូ
លមកវិញបាន។ ព្រះបានធ្វើអា
វពីស្បែកសត្វសម្រាប់អ័ដាម
និងអេវ៉ា។ តើព្រះទ្រង់បា
នយកស្បែកនោះ
ពីណាមក?


កន្លងក្រោយមក អ័ដាម
និងអេវ៉ាក៏បង្កើតបានកូនក្លាយជាគ្រួសារមួយ។
កូនប្រុសច្បងឈ្មោះកាអ៊ីន
គឺជាអ្នកធ្វើចំការ។
កូនទីពីរ
ឈ្មោះអេគឺ
ជាអ្នកគង្វាល
ចៀម។

ថ្ងៃមួយកាអ៊ីនបាននាំយកបន្លែផ្លែឈើមកថ្វាយជាដង្វាយដល់ព្រះ។ អេបិលបាននាំយកសត្វចៀមដែលល្អបំផុតពីហ្វូងចៀមរបស់គាត់មកថ្វាយព្រះ។ ព្រះទ្រង់សព្វព្រះហឫទ័យនឹងដង្វាយរបស់អេបិល។



ព្រះមិនសព្វព្រះហឫទ័យជាមួយនឹងដង្វាយ
របស់កាអ៊ីនទេ។ កាអ៊ីនក៏កើត
មានចិត្តខឹងជាខ្លាំង។ ប៉ុន្តែ
ព្រះទ្រង់មានព្រះបន្ទូលថា
“បើឯងធ្វើល្អ តើមិនបានទឹក
មុខរីករាយវិញ
ទេឬអី?”



កំហឹងរបស់កាអ៊ីនមិនបានបាត់ទេ។
ពេលក្រោយនោះមក កាលនៅឯវាលនៅឡើយ
នោះកាអ៊ីនក៏បានវាយអអបិល
ហើយក៏បានសម្លាប់អេបិល
ចោលទៅ!



ព្រះទ្រង់មានបន្ទូលនឹងកាអ៊ីនថា “តើអេបិលជាប្អូនឯងនៅឯណា?” កាអ៊ីនកុហកថា “ទូលបង្គំមិនដឹងទេ។ តើទូលបង្គំជាអ្នកឃ្វាលប្អូនរបស់ទូលបង្គំឬអ៊ី?”



ព្រះទ្រង់ក៏បានដាក់ទោសអ៊ីនដោយឈប់ឲ្យ
គាត់ធ្វើស្រែចំការទៀត
ហើយបានធ្វើឲ្យគាត់
ត្រូវដើររសាត់អណ្តែតវិញ។



កាអ៊ីនបានចាកចេញពីចំពោះព្រះវត្តមានរបស់ព្រះអម្ចាស់ទៅ។ គាត់ក៏បានរៀបការជាមួយកូនស្រីម្នាក់របស់អ័ដាម និងអេវ៉ា។ រួចពួកគេក៏បង្កើតបានជាគ្រួសារមួយ។



ក្រោយមកមិនយូរប៉ុន្មាន ពួកកូនចៅ
និងចៅទួតរបស់របស់កាអ៊ីនក៏មានគ្នាច្រើន
ពេញក្នុងទីក្រុងមួយដែលពួកគេ
បានកសាងឡើយ។



ទន្ទឹមគ្នានោះដែរ គ្រួសាររបស់អ័ដាម និងអេវ៉ា
ក៏ចេះតែចម្រើនច្រើនឡើងយ៉ាងឆាប់
រហ័ស។ នៅជំនាន់នោះ មនុស្សរស់នៅ
បានអាយុវែងជាងនៅជំនាន់ឥឡូវ
នេះ។



នៅពេលកូនប្រុសម្នាក់ទៀតរបស់នាងបាន
កើតមក នោះអេវ៉ាក៏បាននិយាយថា
“ព្រះទ្រង់បានប្រទានសេតជាជំនួ
សអេបិល។”



សេតគឺជាមនុស្សសុចរិត
ហើយគាត់រស់នៅបានអាយុ៩១២ឆ្នាំ
ក៏មានកូនៗជាច្រើន។



នៅក្នុងពិភពលោក មនុស្សកាន់តែ
មានចំនួនច្រើនឡើង
ហើយអាក្រក់ឡើងៗពី
មួយដំណទៅមួយដំណ។




នៅទីបញ្ចប់ ព្រះទ្រង់សម្រេចព្រះទ័យ
បំផ្លាញមនុស្សលោកចោល
ព្រមទាំង អស់ទាំងសត្វព្រៃ
និងបក្សាបក្សីផង។ ...

... ព្រះទ្រង់ស្ដាយដែលបានបង្កើតមនុស្សមក។ ប៉ុន្តែ មានមនុស្សដែលបានធ្វើឲ្យព្រះគាប់ព្រះហឫទ័យ។ ...




មនុស្សម្នាក់នោះឈ្មោះណូអេ។ ណូអេគឺជា
ពូជជំនាន់ក្រោយរបស់លោកសេត
ហើយក៏ជាមនុស្សសុចរិត
និងរកកន្លែងបន្ទោសមិន
បានផង។ គាត់បាន
ដើរជាមួយព្រះ។


គាត់បានបង្រៀនដល់កូនប្រុសបីនាក់
របស់គាត់ឲ្យស្ដាប់បង្គាប់ព្រះ។ ពេលនោះ
ព្រះទ្រង់មានផែនការនឹងប្រើលោ
កណូអេដោយមធ្យោយដ៏ច
ម្លែក ហើយជាមធ្យោបា
យដ៏ពិសេសមួយ!

ដើមកំណើតនៃសេចក្តីទុក្ខព្រួយរបស់មនុស្ស

រឿងមួយដែលបានមកពីព្រះបន្ទូលរបស់ព្រះ
គឺជាព្រះគម្ពីរ

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ៣-៦

“ការបើកសំដែងព្រះបន្ទូលទ្រង់
នោះផ្សាយពន្លឺចេញ។” ទំនុកដំកើង ១១៩:១៣០

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងអំពីព្រះដ៏អស្ចារ្យរបស់យើង
ដែលបានបង្កើតយើង
ហើយដែលសព្វព្រះទ័យឲ្យអ្នកស្គាល់ដល់ទ្រង់។

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់
ដែលទ្រង់ហៅថាជាអំពើបាប។
ទោសនៃអំពើបាបគឺជាសេចក្តីស្លាប់
ប៉ុន្តែព្រះទ្រង់ស្រឡាញ់អ្នកខ្លាំងណាស់
ទើបទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់តែ១ ព្រះនាមថាព្រះយេស៊ូវ
ឲ្យមកសុគតនៅលើឈើឆ្កាង ហើយឲ្យរងទោសជំនួសអំពើបាបរបស់អ្ន
ក។ បន្ទាប់មក ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ
រួចទ្រង់យាងទៅស្ថានសួគ៌វិញ! ប្រសិនបើអ្នកជឿព្រះយេស៊ូវ
ហើយទូលសូមទ្រង់ឲ្យអភ័យទោសអំពើបាបរបស់អ្នក
នោះទ្រង់នឹងអត់ទោសឲ្យជាពិត! ទ្រង់ក៏នឹងយាងមក
ព្រមទាំងគង់នៅក្នុងជីវិតរបស់អ្នកឥឡូវ
ហើយអ្នកនឹងបានរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿចំពោះសេចក្ដីពិតនេះ
នោះចូរទូលសេចក្ដីនេះដល់ព្រះអង្គថា៖
ព្រះយេស៊ូវអើយ ខ្ញុំជឿថាទ្រង់គឺជាព្រះ
ដែលបានយាងមកកើតជាមនុស្សដើម្បីសុគតជំនួយអំពើបាបរបស់ខ្ញុំ
ហើយទ្រង់ក៏មានព្រះជន្មរស់ឡើងវិញរហូតដល់សព្វថ្ងៃ។
សូមយាងមកគង់ក្នុងជីវិតរបស់ខ្ញុំ
ហើយសូមអភ័យទោសអំពើបាបរបស់ខ្ញុំ
ដើម្បីឲ្យខ្ញុំមានជីវិតថ្មីនាពេលឥឡូវនេះ
រហូតដល់ថ្ងៃដល់ដែលខ្ញុំអាចទៅនៅជាមួយទ្រង់ជារៀងរហូត។
សូមជួយខ្ញុំឲ្យចេះស្ដាប់បង្គាប់ទ្រង់
ហើយរស់នៅសម្រាប់ទ្រង់ក្នុងនាមជាកូនរបស់ព្រះអង្គផង។
អាម៉ែន។

សូមអានព្រះគម្ពីរ ហើយសន្ទនាជាមួយព្រះរាល់ថ្ងៃ!
យ៉ូហាន ៣:១៦